អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ អំពីការយោសប្តិ

www.hoksavann,com

ថ្ងៃទី២២ ធ្នូ ២០១០



ការយោសប្តិ ឬសុបិននិមិត្ត គឺគេឃើញពេលដែលគេទទួលទានដំណោកលក់ទៅ ។ ការទទួលទានដំណោកយោសប្តិ ពេលដែលគេទទួលទានដំណោកលក់ពុំស៊ប់ ។ បើលក់ស៊ប់ គេពុំយោសប្តិឡើយ ភ្ញាក់ឡើងទើបដឹងខ្លួន ។ បើដេកលក់រលីវៗ គេនិយាយនៅឬតែមិនចាប់អារម្មណ៍ ដេកលក់របៀបនេះ ពុំយោសប្តិឡើយ ។ ហេតុអ្វីបានជាមនុស្សត្រូវការទទួលទានដំណោក ? ការទទួលទានដំណោក គឺការសំរាកពីការគិត ព្រោះបើការគិតពុំឈប់ ចលនាសរសៃប្រសាទ ដែលជាប្រព័ន្ធសរសៃខួរក្បាល ក៏ធ្វើការពុំឈប់ដែរ ដែលជាហេតុនាំឲ្យសរសៃប្រសាទទន់ខ្សោយទៅជាមានជម្ងឺ ។ សរសៃប្រសាទក៏ ត្រូវការសំរាកដូចជាអវយវៈដទៃទៀតនៃរាងកាយដែរ ។ តាមធម្មតាមនុស្សបើពុំទទួលទានដំណោក ឬទទួលទានដំណោកពុំលក់តែងតែគិតរវើរវាយជានិច្ច ។ បើពុំសំរាកឲ្យលក់អស់រយៈពេលយូរ នឹងកើតជម្ងឺសរសៃខួរក្បាល ។ គេតែងនិយាយថា គេអាចពុំទទួលទានអាហារមួយពេល កុំឲ្យតែអត់ងងុយ ។ ដូច្នេះការទទួលទានដំណោក ជាអាហារសំខាន់ចាំបាច់របស់មនុស្ស ដើម្បីការរស់រានមានជីវិត កុំឲ្យកើតជម្ងឺដែលទាក់ទងនឹងសរសៃប្រសាទ ។

ការទទួលទានដំណោកយោសប្តិ តាមន័យរបស់ព្រះពុទ្ធសាស នាសំដែងថា មានហេតុច្រើនយ៉ាងគឺ ១- ប្រមាត់កំរើក ប្រមាត់ ជាអង្គធាតុមួយមានមុខងារបញ្ចេញទឹករបស់វាទៅក្នុងក្រពះ ដើម្បីរំលាយអាហារ ។ ទំនងជាប្រមាត់នេះកំរើកដែលមាន ចលនាកំរើកខុសប្រក្រតី ដែលនាំឲ្យមានការយោសប្តិរបៀបរវើរវាយ ។ សព្វថ្ងៃនេះគេអាចកាត់ប្រមាត់ចោលតែម្តង បើប្រមាត់នោះខូចធ្ងន់ពុំអាចព្យាបាលបាន ប៉ុន្តែមនុស្សនោះនៅមានជីវិតធម្មតា ពុំមានគ្រោះថ្នាក់អ្វីឡើយ ។ មានអ្នកខ្លះនិយាយថា ពេលខ្លួនដេកអង្កុញជើងហើយលក់ទៅ ស្រាប់តែឃើញគេដេញចាប់ ខ្លួនគេក៏ខំរត់តែរត់ពុំរួច ត្រង់នេះទំនងជាដេកអង្កុញជើងយូរទៅនាំឲ្យស្លាក់ឈាម បណ្តាលឲ្យយោសប្តិបែបនេះ ។ ២- ធាតុក្នុងខ្លួនប្រព្រឹត្តទៅពុំប្រក្រតី ដូចកំដៅក្នុងខ្លួនខ្លាំងខុសកំដៅធម្មតា ទៅជាគ្រុនក្តៅ ជាហេតុបណ្តាលឲ្យយោសប្តិឃើញរវើរវាយ ។ ៣- គិតច្រើនមុនទទួលទានដំណោកក៏បណ្តាលឲ្យយោសប្តិដែរ ព្រោះគំនិតកង្វល់នោះបានស្ថិតនៅរស់រវើកក្នុងខួរ ក្បាល ។ ៤- ពួកអមនុស្សបណ្តាលឲ្យឃើញ គឺពួកខ្មោចព្រាយបិសាចមកយាយីបៀតបៀន ឬពួកទេវតាបណ្តាលឲ្យឃើញបែបណាមួយ ។ ៥- ធ្វើបុណ្យឬបាបធ្ងន់ៗ ពេលដេកលក់ទៅក៏បណ្តាលឲ្យឃើញតាមសភាពអំពើល្អអាក្រក់របស់ខ្លួន ព្រោះធម្មតាអំពើបាបនិងបុណ្យតែងតែស្ថិតដក់ជាប់ក្នុងចិត្ត លុះដេកលក់ទៅ ក៏វាចេញផុសផុលឲ្យឃើញ ។ ក្រៅពីនេះ ការបរិភោគអាហារច្រើនទៅជាហល់ ធ្វើឲ្យក្រពះពិបាករំលាយ ពេលដេកលក់ទៅនាំឲ្យយោសប្តិរវើរវាយ ដែលខ្មែរហៅថាពុលបាយ ។

តាមអត្ថន័យព្រះពុទ្ធសាសនា ការយោសប្តិបែបណាក៏ដោយ ពុំអាចចាត់ទុកជាបាបជាបុណ្យឡើយ គឺយោសប្តិឃើញធ្វើបុណ្យ ក៏មិនបានបុណ្យ, យោសប្តិឃើញធ្វើបាប ក៏មិនបានបាប ព្រោះមិនមានចេតនាក្នុងពេលដេកលក់នោះ ដោយពុទ្ធភាសិតថា ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនាជាតួកម្ម ។ ការយោសប្តិដោយបាតុហេតុរបស់ផ្លូវកាយនិងផ្លូវចិត្តប្រព្រឹត្តទៅពុំប្រក្រតី បានជាពុំអាចចាត់ជាបុណ្យឬជាបាប ។ ដូច្នេះការយោសប្តិមានលក្ខណៈបែបនេះពុំអាចចាត់ជាការពិតបានឡើយ ។

ផ្ទុយមកវិញ មានយោសប្តិខ្លះបញ្ជាក់ការពិតដែរ ដោយសង្ហា ញសញ្ញាថា អនាគតនឹងកើតមានហេតុបែបណាមួយ ។ យោសប្តិបង្ហាញការពិតនេះ ភាគច្រើនមនុស្សដែលធ្វើអំពើបាបឬ បុណ្យមានទម្ងន់ខ្លាំង ជាពិសេសព្រះពោធិសត្វកសាងបារមីធម៌ ដូចជាព្រះពោធិសត្វព្រះសិទ្ធត្ថចុះចាប់បដិសន្ធិ នាំឲ្យព្រះនាងសិរិមហាមាយាសុបិននិមិត្តឃើញ ។ មួយទៀត មុននឹងបានត្រាស់ជាព្រះពុទ្ធ ព្រះពោធិសត្វបានសុបិននិមិត្តជាហេតុប្រាប់ថា ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធ ។ ចំពោះមនុស្សធម្មតា ក៏មានយោសន្តិបង្ហាញការពិតខ្លះដែរ បើសុខភាពគេល្អ មានចិត្តស្ងប់ តាមការចំណាំយោសប្តិបង្ហាញការពិត ច្រើនពេលជិតភ្លឺ គឺពេលដែលអាហាររលាយក្លាយជាឈាមហើយ ។

ការយកចិត្តទុកដាក់គិតពីយោសប្តិនាំឲ្យកង្វល់ចិត្ត បើយោសប្តិអាក្រក់វិញនាំឲ្យព្រួយចិត្ត ដូច្នេះលោកឲ្យកំណត់ចិត្តបំភ្លេចកុំគិត ទោះបីយោសប្តិបែបណាក៏ដោយ ។ យោសប្តិអាក្រក់ពុំបានអាក្រក់ យោសប្តិល្អពុំបានល្អ ត្រូវតាំងស្មារតីឲ្យរឹងបន្តដំណើរជីវិតតទៅទៀត ។៚

☆ ☆

☆